# សម្រង់សារព័ត៌មានថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧

**១.គេហទំព័រ** rfi

## *លោក សរ វណ្ណារ៉ា៖ «ការសាងសង់សំណង់ខុសច្បាប់នៅតំបន់អង្គរជាកំហុសទាំងអស់គ្នា របស់អ្នកពាក់ព័ន្ធ»*

ដោយ ញឹម សុផល ចុះផ្សាយនៅថ្ងៃ 09/08/2017 (rfi)



នៅថ្ងៃទី៩ខែសីហានេះ គឺជាថ្ងៃឱសានវាទដែលអាជ្ញាធរជាតិអប្សរានិងសាលាខេត្តសៀមរាប កំណត់ឲ្យប្រជាជនដែលបានចូលទៅសាងសង់សំណង់ខុសច្បាប់នៅតំបន់អង្គរកន្លងមកត្រូវស្ម័គ្រចិត្តរុះរើដោយខ្លួនឯង។ បើមិនព្រមរុះរើទេ អាជ្ញាធរនឹងធ្វើការរុះរើដោយមិនយោគយល់នៅថ្ងៃទី១០សីហាស្អែក។ ដោយមិនមានការបញ្ជាក់អ្វីពីសមត្ថកិច្ចនៅថ្ងៃនេះ លោក សរ វណ្ណារ៉ា មន្ត្រីសម្របសម្រួលអង្គការការពារសិទ្ធិមនុស្សលីកាដូប្រចាំខេត្តសៀមរាប បានលើកឡើងថាប្រជាជនបានបង្ហាញជំហររួចហើយថាពួកគាត់មិនរុះរើទេ ដោយសារប្រជាជនទាំងនោះមានការខាតបង់បន្ទាប់ពីខ្ចីបុលគេមកទិញសម្ភារៈសំណង់ ដើម្បីសាងសង់ ដោយមិនមានការហាមឃាត់ពីដំបូង។

**២.គេហទំព័រ** The CAMBODIA DAILY

## *Authorities, Village Residents Set for Clash in Angkor Park*

BY AUN PHEAP AND BRENDAN O'BYRNE | AUGUST 10, 2017 The CAMBODIA DAILY

Authorities confirmed they plan to begin removing more than 500 homes and shops today that they say were built illegally inside Angkor Archaeological Park, while the chief of one of the affected villages said homeowners had no plans to

**៣.គេហទំព័រ** Fresh news

## *ពេលនេះអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប កំពុងរុះរើសំណង់ខុសច្បាប់ នៅរមណីយដ្ឋានអង្គរ ក្រោយបញ្ចប់ឱសានវាទសេចក្តីជូនដំណឹង, ប្រតិបត្តិការរុះរើអាចប្រើពេល ពី១០ថ្ងៃ ទៅកន្លះខែ*

Fresh news 10/08/2017



(សៀមរាប)៖ កម្លាំងរបស់អាជ្ញាធរអប្សរា និងកម្លាំងសមត្ថកិច្ចចម្រុះ របស់គណៈបញ្ជាការឯកភាពខេត្តសៀមរាប នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧នេះ បាននិងកំពុងបើក ប្រតិបត្តិការរុះរើសំណង់ខុសច្បាប់នៅរមណីយដ្ឋានអង្គរ បន្ទាប់ពីរដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា បានចេញសេចក្តីជូនដំណឹងពីវិធានការមួយនេះកាលពីថ្ងៃទី០១ ខែសីហា កន្លងទៅ។

អភិបាលរងខេត្តសៀមរាប ដែលដឹកនាំកម្លាំងប្រតិបត្តិការរុះរើសសំណង់ខុសច្បាប់ លោក លី សំរិទ្ធ បានថ្លែងប្រាប់អង្គភាពព័ត៌មាន Fresh News ឲ្យដឹងថានៅថ្ងៃនេះ អាជ្ញាធរបានធ្វើការរុះរើសំណង់ខុសច្បាប់ទាំងនេះ នៅ៣គោលដៅធំៗរួមមាន៖ ស្រុកប្រាសាទបាគង ស្រុកអង្គរធំ និងក្រុងសៀមរាប (មុខប្រាសាទបន្ទាយក្តី) ហើយ២គោលដៅទៀត នឹងបន្តនៅពេលក្រោយគឺនៅស្រុកពួក និងស្រុកប្រាសាទបន្ទាយស្រី។

បើតាមអភិបាលរងខេត្តរូបនេះ ការរុះរើសំណង់ខុសច្បាប់នៅរមណីយដ្ឋានអង្គរ ក្នុងតំបន់១ និងតំបន់២ អាចប្រើពេលវេលាពី១០ថ្ងៃ ទៅកន្លះខែ ពីព្រោះសំណង់ទាំងនោះ មិនពិបាកក្នុងការរុះរើនោះទេ។

លោក លី សំរិទ្ធ ក៏បានឲ្យដឹងផងដែរថា ប្រតិបត្តិការនៅថ្ងៃនេះម្ចាស់សំណង់ពុំមានការតវ៉ាធ្ងន់ធ្ងរនោះឡើយ លើកលែងតែមានម្នាក់ នៅស្រុកប្រាសាទបាគង ដែលមកយំស្រែកមិនចង់ឲ្យអាជ្ញាធររុះរើ ប៉ុន្តែវិធានការរដ្ឋបាលនេះ នឹងធ្វើឡើងរហូតទទួលបានជោគជ័យ និងបញ្ចប់ជាស្ថាពរ។

ការមិនតវ៉ាធ្ងន់ធ្ងរបែបនេះ ត្រូវបានអភិបាលរងខេត្តអះអាងថា ម្ចាស់សំណង់ខ្លះទទួលយកតាមសេចក្តីជូនដំណឹងរបស់អាជ្ញាធរ ហើយរហូតមកដល់ពេលនេះម្ចាស់សំណង់ ប្រមាណ១០នាក់ បានសម្រេចរុះរើដោយខ្លួនឯង។

សូមរម្លឹកថា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧កន្លងទៅ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរាបានចេញសេចក្តីជូនដំណឹង ជាផ្លូវការមួយ ប្រកាសចាត់វិធានការរុះរើ សំណង់ខុសច្បាប់ស្ថិតក្នុងតំបន់១ និងតំបន់២ នៃរមណីដ្ឋានអង្គរ ចាប់ពីថ្ងៃទី១០ ខែសីហាតទៅ។

យោងតាមសេចក្តីជូនដំណឹងរបស់ស្ថាប័នរដ្ឋទាំង២ បានឲ្យដឹងថា ម្ចាស់សំណាងខុសច្បាប់ដែលសង់ ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងសំណង់ខុសច្បាប់ថ្មីៗ ឬកំពុងសាង់សង់ដោយខុសច្បាប់ផ្សេងទៀត ត្រូវបានអាជ្ញាធរអប្សរា ជូនដំណឹងឲ្យរុះរើដោយស្ម័គ្រចិត្ត ក្នុងរយៈពេល៧ថ្ងៃរួចមកហើយ ប៉ុន្តែម្ចាស់សំណង់មួយចំនួនធំ ពុំទាន់មានការរុះរើដោយខ្លួនឯងនោះទេ។ ដូច្នេះគណៈកម្មការដឹកនាំ និងសម្របសម្រួលលើការរុះរើ សំណង់ខុសច្បាប់ក្នុងតំបន់១ និងតំបន់២ នៃរមណីដ្ឋានអង្គររបស់រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរា សូមទុករយៈពេលចុងក្រោយ ជូនម្ចាស់សំណង់ខាងលើ ដោយស្ម័គ្រចិត្តរុះរើដោយខ្លួនឯង រហូតដល់ថ្ងៃទី០៩ ខែសីហា ជាកំហិត ហើយបើមិនព្រមរុះរើនឹងវិធានការ នៅថ្ងៃបន្ទាប់ដោយពុំទទួលខុសត្រូវ រាល់ការខូចខាត និងបាត់បង់សម្ភារសំណង់នោះឡើយ។

សូមបញ្ជាក់ថា មានសំណង់ខុសច្បាប់ជាង៥០០កន្លែង ត្រូវបានលួចសង់អំឡុងពេលមុនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤នេះ៕

**៤.គេហទំព័រ ដើមអម្ពិល**

## ១.មន្ត្រីជំនាញនិងភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់វគ្គសិក្សា ស្តីពីការគ្រប់គ្រង ទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោក

ព្រហស្បតិ៍, ១០ សីហា ២០១៧ 12:20 ដោយ: ដើមអម្ពិល  ID:039



ភ្នំពេញ៖ មន្ត្រីជំនាញ រួមទាំងប្រធាន និងអនុប្រធានភ្នាក់ងារទេសចរ ប្រចាំនៅតាមប្រាសាទសរុបចំនួន៦៥រូប បានបញ្ចប់វគ្គសិក្សាស្តីពី ការគ្រប់គ្រងទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោក ដោយជោគជ័យ នាព្រឹកថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៧ ក្រោមវត្តមានលោក សុខ សង្វារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍អង្គរ ជាប្រធានបិទកម្មវិធី ។

កម្មវិធីនេះរៀបចំឡើង ដោយអាជ្ញាធរជាតិអប្សរា ក្រោមជំនួយឧបត្ថម្ភរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា ក្នុងក្របខណ្ឌ Fulbright Specialist Program ចាប់ផ្តើមកាលពីថ្ងៃទី១៧ កក្កដា ដល់ថ្ងៃទី៩ សីហា ឆ្នាំ២០១៧។ កម្មវិធីសិក្សានេះបង្រៀន ជាភាសាអង់គ្លេស ដោយលោកស្រីបណ្ឌិត Claudia G.Green ជនជាតិអាមេរិកកាំង មានជំនាញនិងបទពិសោធន៍ បង្រៀនច្រើនប្រទេស ច្រើនឆ្នាំ ស្តីពីការគ្រប់គ្រងទេសចរណ៍ នៅក្នុងតំបន់បេតិកភណ្ឌ ពិភពលោក ។

ថ្លែងក្នុងពិធីបិទវគ្គលោក សុខ សង្វារ ក៏បានថ្លែងអំណរគុណ ចំពោះលោកស្រី Claudia G.Green ដែលបានបំពេញបេសកម្ម បង្រៀនដ៏ល្អដល់ សិក្ខាកាមទាំងអស់ ។

លោកបញ្ជាក់ទៀតថា នេះជាលើកទី២ ហើយនៃវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងទេសចរណ៍នៅក្នុងតំបន់បេតិកភណ្ឌពិភពលោកដល់មន្ត្រី នៅការិយាល័យ រួមទាំងប្រធានក្រុម និងអនុប្រធានប្រចាំតាមប្រាសាទនីមួយៗ។ វគ្គសិក្សាបែងចែកជាពីរក្រុម គឺមន្ត្រីជំនាញនឹងសិក្សា អំពីការងារគ្រប់គ្រងទេសចរណ៍ និតិវិធីរៀបចំគម្រោង ស្ថិតិនិងវិធីសាស្ត្រវិភាគទិន្នន័យ និងសិក្សាអំពីបទពិសោធន៍នៃការគ្រប់គ្រងទេសចរណ៍ពិភពលោក ដោយប្រៀបជាមួយនឹងការ គ្រប់គ្រងទេសចរណ៍ក្នុងតំបន់អង្គរ ។ ចំណែកភ្នាក់ងារទេសចរ នឹងសិក្សាបង្កើនចំណេះដឹង ផ្នែកភាសាអង់គ្លេស សិក្សាអំពីសេវាកម្ម ភូមិសាស្ត្រ និងការងារគ្រប់គ្រងលំហូរភ្ញៀវទេសចរ។ ចំពោះមធ្យោបាយបង្រៀន លោកស្រីបណ្ឌិត Claudia G.Green មានច្រើនមធ្យោបាយ ដូចជាឱ្យអានអត្ថបទ ពិភាក្សាក្នុងថ្នាក់ កិច្ចការផ្ទះ និងមានវីដេអូបង្ហាញផងដែរ ។

លោកក៏បានអំពាវនាវ ដល់សិក្ខាកាមទាំងអស់ សូមយកចំណេះដឹង ដែលទទួលបានពីវគ្គសិក្សានេះទៅផ្សព្វផ្សាយបន្ត និងអនុវត្តឱ្យបានប្រសើរនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ពិសេសខិតខំរកចំណុចល្អ ក្នុងន័យធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរ ដែលមកទស្សនាអង្គរទទួលបានបទពិសោធន៍ដ៏ល្អបំផុត តែផ្តល់ផលប៉ះពាល់ដ៏តិចបំផុត ដល់តំបន់រមណីយដ្ឋានអង្គរ ។

លោក ភឿន សុភាន់ ប្រធានគ្រប់គ្រងភ្នាក់ងារ ទេសចរប្រចាំប្រាសាទភ្នំបាខែង បានសម្តែងនូវការចាប់អារម្មណ៍ថា វគ្គសិក្សានេះធ្វើឱ្យលោកដឹងពីសារៈសំខាន់នៃការធ្វើបដិសណ្ឋារកិច្ច ស្គាល់ពីអាកប្បកិរិយារបស់ ភ្ញៀវមួយចំនួនដូចជា ភ្ញៀវចិន... ដឹងការផ្តល់សេវាកម្មល្អដល់ភ្ញៀវ ថាត្រូវធ្វើបែបណាខ្លះ ពិសេសយល់ដឹងបន្ថែម ផ្នែកភាសាអង់គ្លេស ស្គាល់ភូមិសាស្ត្រ (ប្រទេសដែលភ្ញៀវមក) និងវិធីសាស្ត្រដោះស្រាយ បញ្ហាមួយចំនួនដើម្បីធ្វើឱ្យការ បំពេញការងារប្រចាំថ្ងៃកាន់តែល្អ ។ បន្ថែមពីនោះ លោក ឡេង តុលា ប្រធានភ្នាក់ងារប្រចាំ ប្រាសាទអង្គរវត្ត ក៏បានលើកឡើងពី ឱកាសដ៏ល្អដែលបាន សិក្សាជាមួយសាស្ត្រាចារ្យ លំដាប់ពិភពលោក ដែលមានចំណេះដឹងទូលំទូលាយពាក់ព័ន្ធ នឹងវិស័យទេសចរណ៍យល់ពីស្ថានភាព ទេសចរណ៍ពិភពលោក និងឥរិយាបទរបស់ភ្ញៀវ ។ តាមការបង្រៀនរបស់គាត់ គឺបានផ្តល់វិធីស្រាស្តល្អៗ ជាច្រើនក្នុងការអភិវឌ្ឍ ការងារប្រចាំថ្ងៃ និងជួយបង្កើតប្រសិទ្ធិភាព ក្នុងការចែករំលែកចំណេះដឹង បន្តពីភ្នាក់ងារទៅភ្នាក់ងារ និងពីភ្នាក់ងារទៅភ្ញៀវទេសចរផងដែរ ៕

## *២.ជួបជាមួយអាជ្ញាធរជាតិអប្សរា ក្នុងនាទីព្រឹត្តិការណ៍ព័ត៌មាន*

ថ្ងៃពុធ, 09 សីហា ២០១៧ 20:15 ដោយ: ដើមអម្ពិល ID:019

***៥.គេហទំព័រ* CEN**

## *១.មន្ត្រីជំនាញនិងភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់វគ្គសិក្សា ស្តីពីការគ្រប់គ្រងទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោក*

(ថ្ងៃទី 10 សីហា 2017, ម៉ោង 01:08:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាប: មន្ត្រីជំនាញ រួមទាំងប្រធាន និងអនុប្រធានភ្នាក់ងារទេសចរ ប្រចាំនៅតាមប្រាសាទសរុបចំនួន៦៥រូប បានបញ្ចប់វគ្គសិក្សាស្តីពី ការគ្រប់គ្រងទេសចរណ៍នៅតំបន់បេតិកភណ្ឌពិភពលោក ដោយជោគជ័យ នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ ក្រោមវត្តមានលោក សុខ សង្វារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍អង្គរ ជាប្រធានបិទកម្មវិធី ។

កម្មវិធីនេះរៀបចំឡើង ដោយអាជ្ញាធរជាតិអប្សរា ក្រោមជំនួយឧបត្ថម្ភរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា ក្នុងក្របខណ្ឌ Fulbright Specialist Program ចាប់ផ្តើមកាលពីថ្ងៃទី១៧ កក្កដា ដល់ថ្ងៃទី៩ សីហា ឆ្នាំ២០១៧។ កម្មវិធីសិក្សានេះបង្រៀន ជាភាសាអង់គ្លេស ដោយលោកស្រីបណ្ឌិត Claudia G.Green ជនជាតិអាមេរិកកាំង មានជំនាញនិងបទពិសោធន៍ បង្រៀនច្រើនប្រទេស ច្រើនឆ្នាំ ស្តីពីការគ្រប់គ្រងទេសចរណ៍ នៅក្នុងតំបន់បេតិកភណ្ឌ ពិភពលោក ។

ថ្លែងក្នុងពិធីបិទវគ្គលោក សុខ សង្វារ ក៏បានថ្លែងអំណរគុណ ចំពោះលោកស្រី Claudia G.Green ដែលបានបំពេញបេសកម្ម បង្រៀនដ៏ល្អដល់ សិក្ខាកាមទាំងអស់ ។

លោកបញ្ជាក់ទៀតថា នេះជាលើកទី២ ហើយនៃវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងទេសចរណ៍ នៅក្នុងតំបន់បេតិកភណ្ឌពិភពលោកដល់មន្ត្រី នៅការិយាល័យ រួមទាំងប្រធានក្រុម និងអនុប្រធាន ប្រចាំតាមប្រាសាទនីមួយៗ។ វគ្គសិក្សាបែងចែកជាពីរក្រុម គឺមន្ត្រីជំនាញនឹងសិក្សា អំពីការងារ គ្រប់គ្រងទេសចរណ៍ និតិវិធីរៀបចំគម្រោង ស្ថិតិនិងវិធីសាស្ត្រវិភាគទិន្នន័យ និងសិក្សាអំពីបទ ពិសោធន៍នៃការគ្រប់គ្រងទេសចរណ៍ពិភពលោក ដោយប្រៀបជាមួយនឹងការ គ្រប់គ្រងទេសចរណ៍ ក្នុងតំបន់អង្គរ ។ ចំណែកភ្នាក់ងារទេសចរ នឹងសិក្សាបង្កើនចំណេះដឹង ផ្នែកភាសាអង់គ្លេស សិក្សា អំពីសេវាកម្ម ភូមិសាស្ត្រ និងការងារគ្រប់គ្រងលំហូរភ្ញៀវទេសចរ។ ចំពោះមធ្យោបាយបង្រៀន លោកស្រីបណ្ឌិត Claudia G.Green មានច្រើនមធ្យោបាយ ដូចជាឱ្យអានអត្ថបទ ពិភាក្សាក្នុងថ្នាក់ កិច្ចការផ្ទះ និងមានវីដេអូបង្ហាញផងដែរ ។

លោកក៏បានអំពាវនាវ ដល់សិក្ខាកាមទាំងអស់ សូមយកចំណេះដឹង ដែលទទួលបានពីវគ្គសិក្សានេះ ទៅផ្សព្វផ្សាយបន្ត និងអនុវត្តឱ្យបានប្រសើរនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ពិសេសខិតខំរក ចំណុចល្អ ក្នុងន័យធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរ ដែលមកទស្សនាអង្គរទទួលបានបទពិសោធន៍ដ៏ល្អ បំផុត តែផ្តល់ផលប៉ះពាល់ដ៏តិចបំផុត ដល់តំបន់រមណីយដ្ឋានអង្គរ ។

លោក ភឿន សុភាន់ ប្រធានគ្រប់គ្រងភ្នាក់ងារ ទេសចរប្រចាំប្រាសាទភ្នំបាខែង បានសម្តែងនូវការ ចាប់អារម្មណ៍ថា វគ្គសិក្សានេះធ្វើឱ្យលោកដឹងពីសារៈសំខាន់នៃការធ្វើបដិសណ្ឋារកិច្ច ស្គាល់ពី អាកប្បកិរិយារបស់ ភ្ញៀវមួយចំនួនដូចជា ភ្ញៀវចិន... ដឹងការផ្តល់សេវាកម្មល្អដល់ភ្ញៀវ ថាត្រូវធ្វើ បែបណាខ្លះ ពិសេសយល់ដឹងបន្ថែម ផ្នែកភាសារអង់គ្លេស ស្គាល់ភូមិសាស្ត្រ (ប្រទេសដែលភ្ញៀវ មក) និងវិធីសាស្ត្រដោះស្រាយ បញ្ហាមួយចំនួនដើម្បីធ្វើឱ្យការ បំពេញការងារប្រចាំថ្ងៃកាន់តែល្អ ។

បន្ថែមពីនោះ លោក ឡេង តុលា ប្រធានភ្នាក់ងារប្រចាំ ប្រាសាទអង្គរវត្ត ក៏បានលើកឡើងពី ឱកាស ដ៏ល្អដែលបាន សិក្សាជាមួយសាស្ត្រាចារ្យ លំដាប់ពិភពលោក ដែលមានចំណេះដឹងទូលំទូលាយ ពាក់ព័ន្ធ នឹងវិស័យទេសចរណ៍យល់ពីស្ថានភាព ទេសចរណ៍ពិភពលោក និងឥរិយាបទរបស់ភ្ញៀវ ។ តាមការបង្រៀនរបស់គាត់ គឺបានផ្តល់វិធីស្រាស្តល្អៗ ជាច្រើនក្នុងការអភិវឌ្ឍ ការងារប្រចាំថ្ងៃ និង ជួយបង្កើតប្រសិទ្ធិភាព ក្នុងការចែករំលែកចំណេះដឹង បន្តពីភ្នាក់ងារទៅភ្នាក់ងារ និងពីភ្នាក់ងារទៅ ភ្ញៀវទេសចរផងដែរ ៕ N/S

## *២.ព្រឹត្តិការណ៍ព័ត៌មានរបស់អាជ្ញាធរជាតិអប្សរា សម្រាប់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧*

(ថ្ងៃទី 9 សីហា 2017, ម៉ោង 04:53:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(cen)

: សូមទស្សនាវីដេអូខាងក្រោម៖

**៦.គេហទំព័រ ថ្មីៗ**

## *ការចុះរុះរើសំណង់ខុសច្បាប់នៅតំបន់អង្គរចាប់ផ្ដើមថ្ងៃព្រហស្បតិ៍នេះ*

10, Aug 2017 ,  9:10 am    ដោយ: អ៊ីុសា រ៉ហានី (ថ្មីៗ)




សៀមរាប៖ គណៈកម្មការចម្រុះ ដែលមានសមាសភាពចូលរួមពីអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលខេត្តសៀមរាប នឹងចាប់ផ្ដើមចុះរុះរើសំណង់ខុសច្បាប់នៅតំបន់អង្គរ ចាប់ពីព្រឹកថ្ងៃទី១០សីហាទៅ។ ការចុះរុះរើនេះ ធ្វើឡើងបន្ទាប់ពីមានការពន្យាពេលជាបន្តបន្ទាប់ ដោយសារបញ្ហារៀបចំលិខិតជូនដំណឹងដល់ម្ចាស់សំណង់ទាំងនោះ។

ផ្អែកលើលិខិតជូនដំណឹងរ បស់គណៈកម្មការចុះរុះរើសំណង់កាលពីថ្ងៃទី១សីហា គឺបានកំណត់យកថ្ងៃទី១០ជាថ្ងៃរុះរើសំណង់ខុសច្បាប់។ ការសម្រេចនេះ ក្រោយអាជ្ញាធរបានចុះចែកសេចក្ដីជូនដំណឹងដល់ម្ចាស់សំណង់ទាំងអស់ ឲ្យស្ម័គ្រចិត្តរុះរើដោយខ្លួនឯង តែជាបន្តបន្ទាប់ ម្ចាស់សំណង់មិនបានគោរពទៅតាមសេចក្ដីជូនដំណឹងរបស់អាជ្ញាធរទេ និងខ្លះថែមទាំងបំពានកាន់តែខ្លាំងក្នុងការសង់សំណង់ខុសច្បាប់ក្នុងតំបន់អង្គរ ដែលខ្លះជាប្រភេទសំណង់ស្រាល និងធ្ងន់។

ក្នុងសេចក្ដីជូនដំណឹងដដែល គណៈកម្មការចម្រុះនឹងចាប់ផ្ដើមចុះអនុវត្តវិធានការរុះរើសំណង់ទៅតាមនីតិវិធី ដោយពុំទទួលខុសត្រូវរាល់ការខូចខាតទ្រព្យសម្បត្តិណាមួយឡើយ។

គួរឲ្យដឹងផងដែរថា យោងតាមរបាយការណ៍របស់អាជ្ញាធរជាតិអប្សរា ក្នុងអំឡុងពេលមុនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤នេះ មានសំណង់ខុសច្បាប់ជាង៥០០សំណង់ ដែលលួចសាងសង់ដោយលាក់លៀម ក្នុងរមណីយដ្ឋានអង្គរ បើទោះបីជាអាជ្ញាធរចុះណែនាំក៏ដោយ។ ក្នុងរបាយការណ៍ដាច់ដោយឡែកមួយទៀតរបស់អាជ្ញាធរជាតិអប្សរា មានសំណង់ខុសច្បាប់ចំនួនជាង១០០ករណីទៀត ដែលលួចសាងសង់ក្រោយថ្ងៃបោះឆ្នោត៕